**BMI0129**

# សម្ភាសន៍ជាមួយ មាន សម្បត្តិ ហៅ លឹម ហុង ហៅ អួន ភេទប្រុស អាយុ៥៥ឆ្នាំ

មុខងារសម័យខ្មែរក្រហមៈ អនុប្រធានក្រុមការពារគុកតំបន់៥ ប្រចាំនៅស្រុកថ្មពួក

មុខងារបច្ចុប្បន្នៈ អនុសេនីយ៍ទោកងរេខមរៈភូមិន្ទនៃសឹករងខេត្តបន្ទាយមានជ័យ

ស្រុកកំណើតនៅភូមិរលួស ឃុំស្វាយចេក ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

សព្វថ្ងៃរស់នៅភូមិ ឃុំកំពង់ស្វាយ ក្រុងសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឡុង ដានី

០១:០៨:២៦

៣០ទំព័រ

ដានីៈ ពូអីចឹងដឹបូងខ្ញុំចង់ស្គាល់ឈ្មោះពូ?

សម្បត្តិៈ ឈ្មោះ មាន សម្បត្តិ ។

ដានីៈ ចុះសព្វថ្ងៃពូឈ្មោះអីទៅ?

សម្បត្តិៈ ឈ្មោះ លឹម ហុង ឈ្មោះខ្ញុំទី២ ខ្ញុំស៊ីឈ្មោះគេពេលធ្វើទាហាន ។

ដានីៈ ចុះម៉េចគេហៅពូឈ្មោះអួនវិញ?

សម្បត្តិៈ អានោះឈ្មោះគេហៅក្រៅទេ ឈ្មោះដូចថាក្នុងភូមិអីចឹងណា ឈ្មោះតាមភូមិ បើឈ្មោះក្នុងបញ្ជីជាតិឈ្មោះ សម្បត្តិ ហ្នឹងឯង ឈ្មោះគេហៅក្រៅ អួន ហ្នឹងហើយ ។

ដានីៈ ពូសព្វថ្ងៃអាយុប៉ុន្មានហើយ?

សម្បត្តិៈ ៥៥ ។

ដានីៈ ស្រុកកំណើតកើតជាពូនៅក្នុងភូមិ ឃុំអីដែរ?

សម្បត្តិៈ នៅក្នុងភូមិរលួស ឃុំស្វាយចេក ស្រុកថ្មពួក ខេត្តបាត់ដំបង ។

ដានីៈ ឥឡូវភូមិហ្នឹងគេដូរម៉េចហើយ?

សម្បត្តិៈ រលួស ដដែល ។

ដានីៈ រលួស ដដែល ប៉ុន្តែឃុំអាម៉េច?

សម្បត្តិៈ ភូមិរលួស ឃុំរលួស ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យវិញ ។

ដានីៈ ប្រពន្ធពូគាត់ឈ្មោះអីដែរ?

សម្បត្តិៈ ឈ្មោះ ប៊ូ ភាត់ ។

ដានី៖ គាត់អាយុប៉ុន្មានហើយ?

សម្បត្តិ៖ អាយុ៩៥ឆ្នាំ ដូចគ្នា ។

ដានី៖ សព្វថ្ងៃពូរស់នៅក្នុងភូមិឃុំអីដែរ?

សម្បត្តិ៖ រស់នៅក្នុងភូមិពី ឃុំកំពង់ស្វាយ ក្រុងសេរីសោភ័ណ្ឌ... ។

ដានី៖ សព្វថ្ងៃពូប្រកបមុខរបរធ្វើអី?

សម្បត្តិ៖ ធ្វើយោធាហ្នឹងឯង ។

ដានី៖ ពូតួនាទីអីទៅ?

សម្បត្តិ៖ នៅវង ជីបេ រងការិយាល័យទី២ ។

ដានី៖ សឹករងបន្ទាយមានជ័យ!

សម្បត្តិ៖ ហ្នឹងហើយ ។

ដានី៖ សក្តិប៉ុន្មានអាហ្នឹងពូ?

សម្បត្តិ៖ អនុសេនីយ៍ទោ (សក្តិ២) ។

ដានី៖ ចុះប្រពន្ធពូគាត់ធ្វើអីទៅ?

សម្បត្តិ៖ អត់ធ្វើអីទេ នៅផ្ទះ មេផ្ទះ ។

ដានី៖ ពូមានកូនចៅប៉ុន្មាននាក់ដែរសព្វថ្ងៃ?

សម្បត្តិ៖ ៣នាក់ ។

ដានី៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សម្បត្តិ៖ ស្រីទាំង៣ ។

ដានី៖ ចុះឪពុកពូគាត់ឈ្មោះអីទៅ?

សម្បត្តិ៖ ឈ្មោះ ទុយ វុធ ។

ដានី៖ សព្វថ្ងៃគាត់...

សម្បត្តិ៖ ស្លាប់យូហើយ គាត់ធ្វើទាហានងាប់នៅស្វាយដូនកែវណុះ ។

ដានី៖ ឆ្នាំណាទៅហ្នឹង?

សម្បត្តិ៖ ឆ្នាំមុន៧០ ហុកសិបប៉ុន្មានទេគាត់ស្លាប់នោះ ។

ដានី៖ មុនឆ្នាំ៧០ទៀត?

សម្បត្តិ៖ បាទ! ធ្វើទាហានសម្តេច ។

ដានី៖ ចុះម្តាយ?

សម្បត្តិៈ ម្តាយ ជាម និល ។

ដានីៈ គាត់នៅរស់ ឬក៏ស្លាប់?

សម្បត្តិៈ នៅរស់តើស ។

ដានីៈ សព្វថ្ងៃគាត់នៅឯណា ។

សម្បត្តិៈ សព្វថ្ងៃគាត់នៅភូមិស្វូភី ។

ដានីៈ ឃុំរលួស!

សម្បត្តិៈ ទេ! នៅឃុំកំពង់ស្វាយយើងនេះ ។

ដានីៈ អូ!នៅនេះដែរ!

សម្បត្តិៈ បាទ! នៅនេះដែរតើស ។

ដានីៈ នៅឃុំកំពង់ស្វាយ ក្រុងសេរីសោភ័ណ្ឌ ។

សម្បត្តិៈ បាទ!

ដានីៈ ពូ!បងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់?

សម្បត្តិៈ បងប្អូនទាំងអស់៦នាក់ សុទ្ធតែប្រុសទាំងអស់ ។

ដានីៈ ប្រុសទាំង៦!

សម្បត្តិៈ ប្រុស៥ ស្រី១ ។

ដានីៈ ពូកូនទីប៉ុន្មាន?

សម្បត្តិៈ ខ្ញុំកូនទី២ ។

ដានីៈ កាលពីក្មេងៗពូបានរៀនសូត្រអីដល់ណាដែរ?

សម្បត្តិៈ ខ្ញុំរៀននៅសាលាដល់ថ្នាក់ទី៩ទៅ បានខ្ញុំទៅបួស ។

ដានីៈ កាលរៀននៅថ្នាក់ទី៩ហ្នឹងរៀននៅសាលាណា?

សម្បត្តិៈ សាលាស្វាយចេកនេះឯង ។

ដានីៈ ហើយទៅបួសនៅវត្តណាដែរ?

សម្បត្តិៈ បួសនៅវត្តស្វាយចេកនេះឯង ។

ដានីៈ ពូបួសបានប៉ុន្មានឆ្នាំនៅវត្តស្វាយចេក?

សម្បត្តិៈ បួសបាន៣វស្សា ។

ដានីៈ សឹកនៅឆ្នាំណាទៅពូ?

សម្បត្តិៈ សឹកឆ្នាំ៧៣ បួសឆ្នាំ៧០ សឹកនៅឆ្នាំ៧៣ ។

ដានីៈ ដល់ពេលពូសឹកមកយ៉ាងម៉េចទៀតទៅ ពូទៅធ្វើអីវិញ?

សម្បត្តិៈ ឆ្នាំ៧៣ ធ្វើស្រែធម្មតា ។

ដានីៈ ពូធ្វើស្រែរហូតដល់ពេលណាទៅ?

សម្បត្តិៈ ដល់ឆ្នាំ៧៥ បានធ្វើយោធា ។

ដានីៈ ហេតុអីបានឆ្នាំ៧៥ ពូចូលធ្វើយោធា?

សម្បត្តិៈ កាលហ្នឹងគេរើស គេរើសតាមភូមិ តាមអីហ្នឹង មួយភូមិខ្ញុំហ្នឹង ជាប់បានតែខ្ញុំម្នាក់ទេ ។

ដានីៈ កាលហ្នឹងពូនៅចាំថាគេជ្រើសរើសយ៉ាងម៉េច ហេតុអីបានគេជ្រើសរើសយកតែពូម្នាក់?

សម្បត្តិៈ គេរើសច្រើនដែរ ប៉ុន្តែគេអត់មានស្ម័គ្រចិត្តធ្វើ គេអត់ធ្វើណា អត់មានតំរូវឲ្យធ្វើទេ ។

ដានីៈ អីចឹងពូស្ម័គ្រចិត្តធ្វើ!

សម្បត្តិៈ មិនមែនស្ម័គ្រទេ រើសចំឈ្មោះគឺទៅបណ្ដោយទៅ ។

ដានីៈ អ្នកណាគេ គេមករើសហ្នឹង?

សម្បត្តិៈ អូ! អត់ស្គាល់ទេ កាលហ្នឹងក្មេងអស់បាត់ហើយ មេរើសនោះ មេតាមភូមិ មេភូមិមេអី មេភូមិយើងនៅតាមមូលដ្ឋានហ្នឹង យោធាវាមក ប៉ុន្តែយើងវាអត់ស្គាល់យោធាវាមករើសណា បានក្រោយមកទៀតបានសម័យប៉ុជន ប៉ុអីនោះ គេទើបនឹងសន្តិភាព អត់ស្គាល់មេគេទេ មេទ័ពគេ ។

ដានីៈ កាលហ្នឹងមេភូមិឈ្មោះអី?

សម្បត្តិៈ តាពេញ ។

ដានីៈ គាត់អ្នកភូមិជាមួយពូដែរ?

សម្បត្តិៈ អ្នកភូមិរលួសនោះឯង គាត់អ្នកភូមិចាស់ យោធាប្រាប់មេភូមិទៅ មេភូមិរើស ។

ដានីៈ ចុះបន្ទាប់ពីជ្រើសរើសហើយយ៉ាងម៉េចទៀតទៅពូ?

សម្បត្តិៈ គេបញ្ជូនខ្ញុំទៅថ្នពួក គេប្រមូលម្ដុំម៉ាន្លែងវរៈគេនោះណានៅណុះហ្នឹងណា នៅណុះកាលណុះ ៥១៣ និង ៤២៥ ហើយនៅនោះ៤២៥ លេខវរៈណា ។

ដានីៈ សេនាតូច ឬសេនាធំ?

សម្បត្តិៈ សេនាតូច ។

ដានីៈ ៤២៥!

សម្បត្តិៈ ៤២៥ ។

ឡាយុំៈ កងពលលេខប៉ុន្មាន?

សម្បត្តិៈ អូ! អានេះតំបន់ គេមិនដែលមានប្រកាសកងពលផង មាន២វរៈ វរៈនៅហ្នឹងមួយ មួយវរៈទៅនោះ អានេះ៥១៣ ។

ឡាយ៉ុំៈ ៤២៥ អាហ្នឹងយោធាស្រុក?

សម្បត្តិៈ អត់ទេ! យោធាតំបន់ យោធាស្រុកអាប៊ិ ភា នៅប្រចាំស្រុក អានោះយោធាស្រុកគេមានលេខទ័ពស្រុក ខ្ញុំនៅតំបន់ ។

ដានីៈ អីចឹងពូនៅតំបន់?

សម្បត្តិៈ បាទ!

ដានីៈ កាលហ្នុងវរៈរបស់ពូនៅថ្មពួក?

សម្បត្តិៈ នៅថ្មពួក ។

ដានីៈ កាលហ្នុងយ៉ាំងម៉េចទៅកាលយើងមកដល់ថ្មពួក យើងយ៉ាំងម៉េ?

សម្បត្តិៈ គេប្រមូលផ្តុំនៅនោះឯងធ្វើការងារ ហីបំបែក បែងចែកទៅតាមព្រំដែនផង ហីខ្ញុំនៅការពារឃ្លាំងថ្មពួកកាលណុះ នៅការពារឃ្លាំងថ្មពួកណា ។

ដានីៈ នៅការពារឃ្លាំងថ្មពួក?

សម្បត្តិៈ បាទ! ឃ្លាំងគ្រាប់ ឃ្លាំងអី កាំភ្លើងគេប្រមូល អា..អីណាគេប្រមូលណា កាំភ្លើងស្អីគ្រប់ទាំងអស់ យកមកដាក់នៅខាងលិចផ្លូវហ្នុង ។

ដានីៈ កាលហ្នុងពូមានតួនាទីទេ?

សម្បត្តិៈ ខ្ញុំនៅអនុក្រុម អាសួត វាមេក្រុម ។

ដានីៈ យ៉ាំងម៉េចទៅកាលនៅថ្មពួកហ្នុង ដូចថាការពារឃ្លាំងហ្នុងយើងធ្វើអីខ្លះទៅ?

សម្បត្តិៈ កាលណុះ គេដាក់សន្តិសុខនៅកន្លែងនោះឯង គេដាក់គុកនៅកន្លែងនោះឯង រួចយើងយាមមើល ។

ដានីៈ គុករបស់តំបន់អាហ្នុង?

សម្បត្តិៈ គុករបស់តំបន់ហើយ ព្រោះបញ្ហា... ។

ឡាយ៉ុំៈ នៅត្រង់ណាឥឡូវនេះ ឃ្លាំងហ្នុងទីតាំងឥឡូវ?

សម្បត្តិៈ នៅនេះលោកគ្រូ នៅអា សាលារៀននៅអីចេះ វាមកអីចេះអាកន្លែងហ្នុងមានដើមត្រាចផ្ទះទទួលភ្ញៀវពីដើមនោះ ផ្ទះទទួលភ្ញៀវពីដើមខ្ញុំនៅលិច ទៅជើងណាខាងជើងផ្សារ ម៉ុំស្ពានណា ចេញពីស្ពានទៅចំងាយប្រហែល១៥០ម៉ែត្រ នៅខាងលិចផ្លូវ ។

ឡាយ៉ុំៈ នៅកន្លែងសេវ៉ាហ្នុងមិនដឹង?

សម្បត្តិៈ នៅខាងជើងផ្សារ ម្តុំប្រឡាយថ្នល់នោះឯង វានៅខាងជើងផ្សារមកពីកើតនេះណា មកពីផ្លូវជាតិនេះណា ផ្លូវបន្ទាយឆ្មារអីចេះ ។

ដានីៈ កន្លែងគុក កន្លែងសន្តិសុខហ្នឹង កន្លែងសន្តិសុខរបស់ថ្នពួក ឬរបស់តំបន់៥?

សម្បត្តិៈ របស់តំបន់ហើយ ព្រោះបញ្ជូនមកស្វាយនេះ ។

ដានីៈ ពូនៅហ្នុង យើងធ្វើសន្តិសុខហ្នុង មានគ្នាប៉ុន្មាននាក់ទៅ?

សម្បត្តិៈ សន្តិសុខគ្នា៧នាក់ ។

ដានីៈ ឈ្មោះ សួត គាត់មេក្រុម?

សម្បត្តិៈ បាទ! មេក្រុម ។

ដានីៈ ហើពូអនុក្រុម?

សម្បត្តិៈ បាទ!

វណ្ណៈៈ ចុះគុក សន្តិសុខហ្នុងបង្កើតតាំងពីឆ្នាំណាមក?

សម្បត្តិៈ បង្កើតឆ្នាំណាទេ ឆ្នាំ៧៥ ប្រហែល៧៦, ៧៧ ។

វណ្ណៈៈ ៧៧ បានបង្កើតគុក!

សម្បត្តិៈ បាទ!

វណ្ណៈៈ ចុះអ្នកដែលមកជាប់គុកហ្នឹងជាអ្នកជាប់ទិន្នាការហើគេយកមកពីខាងណាមកដាក់នៅហ្នឹង?

សម្បត្តិៈ អត់ទេ! គេចាប់បានគេបញ្ជូនមកហ្នឹង មិនដឹងគេចាប់បានពីណាពីណើមកគេបញ្ជូនមកទល់ត្រឹមនោះឯង ។

ឡាយុំៈ គុកកាលហ្នុងភាគច្រើនពីរឿងទស្សនៈនយោបាយ?

សម្បត្តិៈ អត់ទេ! លោកគ្រូ ។

ឡាយុំៈ មានខុសសីលធម៌ មានអី...

សម្បត្តិៈ អូ! អត់ទេ អត់មានបញ្ជូនមកទេអាអីចឹងៗនោះ មិនដែលមានទេ ក្នុងនោះ អ្នកនៅក្នុងថ្នពួកនោះអត់ដែលមានបញ្ជូនមកក្នុងគុកនោះទេ មានតែចាប់បានពីក្រៅពីខ្សែត្រៀមឯណាឯណើបញ្ជូនមក អ្នកដែលថាជម្លៀសអីណាណើរត់លិចកើត អានោះចាប់បានបានបញ្ជូនមក ។

ដានីៈ ពូអាចជួយរៀបរាប់ដូចថាយើងសន្តិសុខនៅហ្នឹង ឧបមាថាយើងត្រូវធ្វើម៉េច យើងត្រូវចាប់អ្នកទោស ឬបញ្ជូនអ្នកទោសអីមកយ៉ាងម៉េចៗអីមកយ៉ាងម៉េចៗ ពូនៅចាំអាចជួយរៀបរាប់?

សម្បត្តិៈ អានោះតាមយោធាខ្លះ យោធាមិនសូវទេ តាមភូមិតាមអី ប៉ះខ្សែត្រៀមគេ គេចាប់ដូចថាឈ្លបអីចាប់ពេលរត់ពេលអីណា តាមព្រៃតាមអីទៅ ពេលគេចាប់បានគេបញ្ជូនមកកន្លែងនោះឯង អារឿងរ៉ាវណាខ្លះដែលអាចបញ្ជូនមកស្វាយ មកស្វាយទៅ អាខ្លះវៃចោលនៅនោះឯង វៃចោលនោះមានស្រីមានអី កាលណុះមាននារីមានអីចូលរួមវៃដែរណា ពួកមីកាអេង មីយន វាសុទ្ធតែប្រធាននារីកាលណុះគេមិនទាន់កាត់នារីសេនាជនចេញអស់ទេ នៅនារីសេនាជននៅ ។

វណ្ណៈ អីចឹងនារីក៏មានសិទ្ធធ្វើសេជនធ្វើឈ្លបធ្វើអីដែរ?

សម្បត្តិៈ ធ្វើសេនាជន ធ្វើយោធាដូចគ្នានោះឯង យោធាស្រីនោះ ។

ឡាយុំៈ យោធាស្រុកឬ?

សម្បត្តិៈ យោធាតំបន់ ។

ឡាយុំៈ គុកជិនាន់ហ្នុងអត់ដូចគុកឥឡូវទេ គុកឥឡូវវាមានទោសច្រើនណា!

សម្បត្តិៈ បាទ!

ដានីៈ គុកកាលភាគច្រើនតែរឿងនិន្នាការហ្នឹងទេ?

សម្បត្តិៈ ទើសតែឃើញអ្នករត់ហ្នុងហើយ បញ្ជូនអ្នករត់ដែលគេចាប់បានតាមភូមិតាមអីហ្នុង បញ្ចូលទៅនោះឯង ឆ្លងដែនអីណាណីទៅ ។

ដានីៈ អ្នករត់ទៅណា?

សម្បត្តិៈ អ្នករត់ទៅថៃហ្នុងឯង អ្នកជម្មៀសមកតាមស្វាយ តាមអីនោះតាមព្រះនេត្រព្រះ រត់ទៅថៃឆ្លងទៅគេចាប់បានគេបញ្ជូនទៅនោះឯង ។

ដានីៈ ឆ្នាំណាដែលភាគច្រើនដែលរត់ទៅប្រទេសថៃ?

សម្បត្តិៈ ឆ្នាំ១៩៧៦,៧៧ ហ្នឹងឯងភាគច្រើន ។

ដានីៈ ចុះពួមកធ្វើសន្តិសុខហ្នឹងតាំងពីឆ្នាំ៧៥មក ដូចថាឆ្នាំ៧៥គេរើសអីតាមភូមិអីហើយគេបញ្ជូនមក?

សម្បត្តិៈ គេធ្វើនៅនោះហើយ ខ្ញុំនៅតែដូចពីដើម ខ្ញុំនៅយាមឃ្លាំងហើយយាមគុកនោះបណ្តោយ ។

ដានីៈ យាមឃ្លាំងហើយយាមគុក?

សម្បត្តិៈ បាទ!

ដានីៈ យាមឃ្លាំងផង យាមគុកផង ឬយ៉ាំងម៉េច?

សម្បត្តិៈ ហ្នឹងហើយយាមឃ្លាំងផង យាមគុកផង អាឃ្លាំងនោះផ្ទះធំ វាដាក់កាំភ្លើងលើនោះ កាំភ្លើងគ្រាប់អី ហីគុកដាក់នៅឯត្បូងអីចេះទាប ។

វណ្ណៈ មានប៉ុន្មានខ្នងដែរ គុកនៅត្រង់ហ្នឹង?

សម្បត្តិៈ គុកមានតែមួយខ្នងហ្នឹងឯង ៤,៥ ប្រលោះ ។

វណ្ណៈ ដាក់មុនស្សប្រហែលបានប៉ុន្មាននាក់ដែរម្តង?

សម្បត្តិៈ ទេ! ដាក់បាន៧,៨នាក់ដែរណា ។

ដានីៈ អីចឹងមួយចំនួនគេវៃចោលនៅហ្នឹង ហីម៉ាចំនួនគេបញ្ជូនមកស្វាយ ហីអ្នកដែលគេវៃចោលយ៉ាងម៉េច បានជាគេវៃចោលនៅហ្នឹង ហីអ្នកដែលយ៉ាងម៉េចបានគេបញ្ជូនមកស្វាយ?

សម្បត្តិៈ អានោះស្រេចតែគេអ្នកសួរចម្លើយថាត្រូវបញ្ជូនយ៉ាងម៉េចៗខ្ញុំអត់ដឹងទេ ។

ឡាយុំៈ អ្នកណាអ្នកសួរ?

សម្បត្តិៈ អូអត់បានចាំទេ គេអ្នកសួររួច គេត្រូវបញ្ជូនទៅ គេបញ្ជូនទៅ ។

វណ្ណៈ គ្រាន់តែចាំការពារខាងក្រៅ?

សម្បត្តិៈ បាទ! ខ្ញុំការពារកុំឲ្យវារួច កុំឲ្យវាស៊ីប៉ុណ្ណឹងឯង កុំឲ្យវាបាត់កាំភ្លើង កុំឲ្យវារួចមនុស្សនោះឯង គេសួររួចគេត្រូវបញ្ជូនយ៉ាងម៉េច គេមិនបានប្រាប់ខ្ញុំ គេថាថ្ងៃនេះ គេត្រូវបញ្ជូនមនុស្ស២នាក់ទៅ បញ្ជូនហ្នឹងក៏មិនដឹងគេបញ្ជូនទៅស្វាយ ឬក៏គេសម្លាប់ចោលតាមផ្លូវ បើអាសម្លាប់តាមនោះវាធ្លាប់មានដែរ គេបញ្ជាថាឲ្យសម្លាប់ហើយ ក៏ព្រាងព្រាតទៅនារីសេនាជនអី ។

ឡាយុំៈ សម្លាប់ក្នុងហ្នឹងម៉ង ក្នុងគុកហ្នឹង?

សម្បត្តិៈ អត់ទេ! យកទៅសម្លាប់នៅក្រោយណុះ ។

វណ្ណៈ ព្រៃក្រោយណុះ!

សម្បត្តិៈ ព្រៃក្រោយណុះ ។

វណ្ណៈ ចុះរចនាសម្ព័ន្ធពីថ្នាក់តំបន់ចុះមកក្រោម ពូអាចរៀបរាប់បានទេ ពូអាចស្គាល់ពីប្រធានតំបន់ចុះៗមកអី គណៈតំបន់៥ អីណា ពូអាចដឹងបានស្គាល់ខ្លះៗទេ?

សម្បត្តិៈ គណៈតំបន់៥ អ្នកណាគេ តាធន កាលណុះ អត់បានចាំទេ ប៉ិ ឆាត ចៅហ្វាយស្រុកអ្នកណាទេ ។

ដានីៈ ចុះ ហ៊ីង អីនោះ?

សម្បត្តិៈ តាហ៊ីន ភូមិភាគហើយនោះ របនាសម្ព័ន្ធបើដូចខ្ញុំធ្វើការរាល់ថ្ងៃបានដឹង ពីមុនអត់ដឹងថាម៉េចៗទេ ។

ដានីៈ ចុះប្រធានសន្តិសុខកន្លែងពូឈ្មោះអីទៅ?

សម្បត្តិៈ ប្រធានសន្តិសុខមានតែមកមួយភ្លែតៗ ខ្ញុំហើយនៅនោះ នៅអាល់ឡាដីមើលខុសត្រូវ ។

ដានីៈ ពូអ្នកមើលខុសត្រូវនៅហ្នឹង?

សម្បត្តិៈ ហ្នឹងហើយ អារួចមិនរួច លែងមិនលែងអី ។

ដានីៈ លើពូ!

សម្បត្តិៈ ហ្នឹងហើយ គេប្រាប់ថាឈ្មោះនេះយកទៅសួរចម្លើយអាផ្ទះត្បូង អាផ្ទះជញ្ជាំងជិតនោះ គេយកទៅសួរចម្លើយទៅ ខ្ញុំនៅចាំទៅ ឲ្យកូនចៅ២នាក់តាមទៅមើលខ្លាចរួចអីម៉េចៗ គេសួរចម្លើយរួចក៏យកបញ្ចូលមកវិញ វៃស្នៀតដាក់ស្នូកទៅ ដាក់រ៉ូស៊ីវៃ...

ឡាយុំៈ ដាក់ខ្នោះទេ?

សម្បត្តិៈ ដាក់ខ្នោះជើង ធ្វើក្របបោះម៉ាកំរល់ៗដាក់សឹកទៅគេដាក់រ៉ូស៊ីរឹបអីចេះទៅ គេស្មានអីចេះទៅគេដាក់ឈើពីលើមួយទៀតទៅ គេវៃ...សងខាងអត់មានទៅរួចទេ

វណ្ណៈ ខ្នោះដៃ ឬដៃជើង?

សម្បត្តិៈ អត់មានខ្នោះដៃទេ មានខ្នោះជើងដាក់រ៉ូស៊ី ខ្នោះក្រប ម៉ាក្រប មិនទាន់ដាក់រ៉ូស៊ីគេសឹកបានដល់ដាក់រ៉ូស៊ីរឹបអីចឹងទៅ មួលគ្រឹបៗ ។

ឡាយុំៈ គេមួលដែរ!

សម្បត្តិៈ មួល! ខ្លះមិនបាច់មួលផងគ្រាន់តែសឹកពីក្រោម រុញអាមួយពីលើសម្ងាប់សម្ងាប់អាក្បាលរ៉ូស៊ីនោះ កុំឲ្យវាងើបចុះងើបឡើង ។

អ្នកជិតខាងៈ យើងសម័យរដ្ឋកម្ពុជាក៏មានដែរអាគុកអីចឹងៗ ។

ដានីៈ អីចឹងពូ អ្នកសួរចម្លើយមិនមែនក្រុមរបស់ពូអ្នកសួរទេ?

សម្បត្តិៈ មិនមែនទេ ខាងតំបន់គេ គេត្រូវសួរ ការងារគេយើងមិនសូវដឹងផង យើងដឹងតែ រួចមិនរួច បើរួចគេធ្វើទោសយើងហើយ បើលែងអីម៉េច មានរឿងដល់យើងហើយ ។

ដានីៈ ពូអ្នកនាំឲ្យគេ?

សម្បត្តិៈ បាទ!

ដានីៈ គេសួរ មានបន្ទប់គេសួរអី?

សម្បត្តិៈ មានបន្ទប់ មានផ្ទះគេធំប៉ុណ្ណេះអី ជញ្ជាំងជិត ប៉ុនច្រើនដែរងាប់ដោយវ៉ៃចោលនោះច្រើន គ្រាន់ខ្ទង់រយហើយ ។

ដានីៈ អ្នកសួរចម្លើយនៅជាមួយពូដែរអត់?

សម្បត្តិៈ អត់ទេ! អ្នកសួរចម្លើយនៅជាមួយតំបន់ នៅជាមួយ.. ប្រពន្ធខ្ញុំបានស្គាល់ ធា...

ឡាយុំៈ ចុះអ្នកណាគេជាពេជ្ឈឃាត?

សម្បត្តិៈ ពេជ្ឈឃាតជារួមទេ អត់ដឹងថាអ្នកណាៗទេ ពេលណាគេត្រូវការទៅ អានេះចាប់មួយ អានោះចាប់ៗទៅណាស្រីប្រុស សេនាជនប្រុសផង ។

ឡាយុំៈ រួមហ្នឹង ស្រេចតែគេចាត់តាំងទេន៎ គេចាត់តាំងឲ្យអ្នកទៅ អ្នកហ្នុងទៅទៅ?

សម្បត្តិៈ បាទ! មានអាអ្នកដឹកអន្ទុង មានអាអ្នកយកទៅវ៉ៃ ទៅវ៉ៃយប់ម៉ោង៦, ៧ អីយកទៅ ហើយ ។

ដានីៈ ដល់គេសួរហើយ គេប្រាប់ពួកពូទៅ ដូចថាអ្នកណាត្រូវ...

សម្បត្តិៈ បាទ! អ្នកណាត្រូវវ៉ៃ ។

ដានីៈ បាទ! ប្រាប់ថាអ្នកនេះត្រូវវ៉ៃចោល...

សម្បត្តិៈ បាទ! អ្នកនេះត្រូវវ៉ៃចោល ឈ្មោះនេះៗ អ្នកណាត្រូវបញ្ជូនទៅស្វាយ ។

ដានីៈ រួចទៅយើងចាត់ចែងទៅ អ្នកណាត្រូវយកទៅ យកទៅ...

សម្បត្តិៈ ដោះតាមនោះឯង ដោះតាមឈ្មោះនោះឯង ។

ឡាយុំៈ អ្នកទោសហ្នុងមានអង្ករកយើងអីទេ?

សម្បត្តិៈ អូ! វាអង្ករឡើងហៀរអាចម៍ អង្ករស្អីខ្មែរក្រហមនោះ ស្រណោះវាស្រណោះហើយ ប៉ុនមិន ដឹងធ្វើម៉េចបើញ្ញាគេ ។

ដានីៈ គេបញ្ជាហើយយើងត្រូវតែធ្វើន៎?

សម្បត្តិៈ បាទ! កាលហ្នុងងាប់ច្រើនណាស់ ថាខ្ទង់រយទៅចុះ អាត្បូងសាលាកូលេសនោះមួយកន្លែង ដែរ វ៉ៃចោលត្រង់ណុះ ។

ដានីៈ ខាងត្បូងសាលាកូលេសនៅឯណា?

សម្បត្តិៈ ត្បូងសាលាកូលេសនៅថ្មពួក ។

ឡាយុំៈ វិទ្យាល័យថ្មពួក!

សម្បត្តិៈ ហ្នុងហើយវិទ្យាល័យ ។

វណ្ណៈៈ អីចឹងមានទីតាំង២!

សម្បត្តិៈ មានទីតាំង២ ។

វណ្ណៈ ចុះអ្នកដែលជាប់នៅហ្នឹងជាប្រភេទយ៉ាងម៉េច ប្រភេទអ្នកទោសហ្នឹង អ្នក១៧ មេសា ឬក៏អ្នកជាប់និន្នាការយ៉ាងម៉េចដែរពូ?

សម្បត្តិៈ ច្រើនពួកអ្នកភ្នំពេញអីរត់ មកពីភ្នំពេញជម្លៀសមកតាមចំការ តាមព្រះនេត្រព្រះ តាមស្វាយតាមអីរត់គេចខ្លួនឆ្លងដែនទៅ រត់ទៅវាអត់ផុត ពួកជីវពល ពួកឈ្លបអីចាប់បានទៅបញ្ជូនទៅនោះទៅ ។

ដានីៈ ចុះដូចថារបៀប អ្នកដែលត្រូវវៃចោលយើងវៃយ៉ាងម៉េច យើងយកកាំភ្លើងបាញ់ ឬវៃ...

សម្បត្តិៈ អត់ទេ! វៃនឹងត្បូងចប ។

ដានីៈ ដាក់របៀបយ៉ាងម៉េច ពេលដែលយើងវៃនោះ យើង...

សម្បត្តិៈ ជីកអន្លុងហើយឲ្យអង្គុយ ដូចថានេះអន្លុងអីចឹងណា ឲ្យអង្គុយតាមមាត់អន្លុងអីចេះឯង វៃទម្លាក់អន្លុង ។

ដានីៈ ចងដែរអត់?

សម្បត្តិៈ ចងតើស! បើមិនចងរត់អស់ហើយ សើច... ។

ដានីៈ របៀបចងនោះចងយ៉ាម៉េចទៅ?

សម្បត្តិៈ ចងនឹងខ្សែអង្រឹងនេះឯង ។

ដានីៈ ចងដៃទៅមុខ ឬចង...

សម្បត្តិៈ ទេ! ចងដៃទៅក្រោយទាំងអស់ ។

ដានីៈ ហើមុខអីមានបិទដែរអត់?

សម្បត្តិៈ អត់ទេ មិនបិទទេ!

ដានីៈ ហើយើងយកត្បូងចបវៃពីក្រោយ?

សម្បត្តិៈ វៃពីក្រោយ ។

ដានីៈ អន្លុងហ្នឹងយើងជីកខ្លួនឯង ឬឲ្យអ្នកទោសហ្នឹងអ្នកជីក?

សម្បត្តិៈ អត់ទេ ជីកខ្លួនឯង យោធាគេអ្នកទៅជីក កូនចៅខ្ញុំហ្នឹងឯង ។

វណ្ណៈ ពេលដែលវៃស្លាប់ហើយយើងស្រាយចំណងវិញ ឬក៏មិនស្រាយ?

សម្បត្តិៈ ស្រាយ! ស្រាយយកខ្សែអង្រឹងហ្នុងឯង ។

ឡាយុំៈ បើមិនស្រាយយើងមានខ្សែណាចងក្រោយ!

សម្បត្តិៈ សើច!

ដានី៖ ចុះខោអាវ យើងវៃហើយយើងមានដោះខោយកទេ?

សម្បត្តិ៖ អត់ទេ! មិនដែលដោះទេ ដោះម៉េចឈាម ។

ឡាយុំ៖ ចុះមាសប្រាក់អលង្ការអី អត់មានឆែករកទុកទេ?

សម្បត្តិ៖ មិនដែលមានផង គេចាប់មកគេឆែកយកអស់ហើយ ពួកអាជីវពល ឈ្លបអីគេឆែកយកមុនអស់ហើយ មាន! មិនអត់ទេ ប៉ុនអាពួកនោះឆែកបាន ។

ឡាយុំ៖ ចុះមានស្រីស្អាតអី ឃើញទំនងអីដាក់សិន?

សម្បត្តិ៖ អូ! ដែលមាន មិនហ៊ានទេ បើអីចុងដាច់ខាតគឺដែរអត់មានទេ ។

ដានី៖ គេហាម ឬក៏យើងអត់ហ៊ាន?

សម្បត្តិ៖ អូ! ខុសសីលធម៌ មិនបានទេ វាឃើញស្រេចបណ្ដោយ ផាប់ក្លាម យោធាខាងណាក៏ដោយមានស្អាតៗពួកអ្នកភ្នំពេញនោះ ដែលស្គាល់ស្រែស្រូវឯណា ។

ដានី៖ ពួអ្នកដែលគេត្រូវវៃចោលគេច្រើនតែវៃពេលណា?

សម្បត្តិ៖ ច្រើនតែម៉ោង៧ ។

ដានី៖ ៧យប់!

សម្បត្តិ៖ ៧, ៨ មិនទៀង ៧យប់ ។

ដានី៖ ពេលយើងវៃហ្នុងយើងមានចាក់មេក្រូចាក់អីបន្ទំ ឬក៏កន្លែងវៃនោះឆ្ងាយពី...

សម្បត្តិ៖ អូ! មិនមានចាក់មីក្រូបន្តិចទេ គ្មានប្រជាជនណាហ៊ានក្អកបន្តិចទេ ប្រជាជនជិតៗស្ងាត់ច្រៀប ។

ដានី៖ ដល់ពេលយើងវៃ យើងលប់ ឬអត់លប់ទេរណ្ដៅនោះ?

សម្បត្តិ៖ អូ! លប់ណា លប់ស្អាត ។

ដានី៖ ចុះមួយរណ្ដៅៗហ្នុងវៃម្ដងប៉ុន្មាននាក់ទៅ?

សម្បត្តិ៖ ជួនកាល៥នាក់ ជួនកាល៤ ជួនកាល៣ ។

ដានី៖ មានស្រី មានប្រុសវៃលាយចូលគ្នា ឬក៏យើងបែងចែក?

សម្បត្តិ៖ វៃលាយប្រុស លាយស្រី ។

ដានី៖ ចុះពួពេលដែលយើងរៀបវៃហ្នុងយ៉ាងម៉េចទៅ អ្នកដែលនេះហ្នឹងដូចថាមាននិយាយអីថាយ៉ាងម៉េចៗទេ?

សម្បត្តិ៖ អូ! និយាយតើស ស្ដាប់ម៉េចបាននិយាយច្រើនខ្សែពេកនោះឯង និយាយសុំអនុវអីណាណីខ្ញុំស្មោះត្រង់អីណាណី និយាយច្រើន ។

ដានីៈ កាលហ្នឹងពូទទួលបន្ទុកហ្នឹងពីឆ្នាំណាដល់ឆ្នាំណា ពេលវៃហ្នឹង?

សម្បត្តិៈ ៧៦ ហើយបានធ្វើគុក ៧៦, ៧៧ ដល់ចុងឆ្នាំ ៧៧គេឲ្យខ្ញុំទៅនៅព្រំដែនទៅក្បាលរមាស នៅឆ្នូក ៧៧ខ្ញុំទៅណុះ ខ្ញុំឈប់នៅកន្លែងនោះហើយ ។

ដានីៈ ចុះពូ ចន្លោះពី៧៦, ៧៧ហ្នឹង បើពូបាំនស្មានមើល វៃប្រហែលប៉ុន្មានដង មួយខែៗ ប៉ុន្មានដង ឬក៏វៃរាល់ថ្ងៃ?

សម្បត្តិៈ អត់វៃរាល់ថ្ងៃទេ ជូនកាលមួយអាទិត្យ ៥នាក់ , ៣នាក់ នៅគុកនោះមិនដែលដាច់ទេ ដាច់ក៏ដាច់តិចណាស់មនុស្ស ។

ដានីៈ មិនដែលដាច់ទេមនុស្សចូលមករហូតឬ?

សម្បត្តិៈ មិនដែលដាច់ទេ ចុះពីណាពីណីមកចូលតែមួយកន្លែងហ្នឹងឯង ។

ដានីៈ អីចឹងច្រើនតែអ្នកភ្នំពេញអ្នកអីទេ អ្នកមូលដ្ឋានអត់...

សម្បត្តិៈ បាទ! អ្នកភ្នំពេញ បើអ្នកមូលដ្ឋាន ដូចថាខុសសីលធម៌អីហ្នឹងសហករណ៍គេវៃអីមិនដឹងទេ ។

ដានីៈ ចុះពូអ្នកសម្រេចថាយើងវៃ ឲ្យយើងបញ្ជូនមកស្លាយអ្នកណាគេអ្នកសម្រេច?

សម្បត្តិៈ តំបន់! តំបន់ឈ្មោះ ប្រពន្ធគាត់ឈ្មោះភា អូ! ប៉ិ ធន សម័យហ្នឹង ប៉ិ ធន ហ្នឹងឯង ។

ដានីៈ ឈ្មោះអី?

សម្បត្តិៈ ធន ។

ដានីៈ ធន ហ្នឹងគាត់ប្រាប់ថាអ្នកនេះយើងត្រូវកម្ទេចចោល...

សម្បត្តិៈ គាត់ដូចថា ភូមិភាគដូរមុខអីចឹងណា គាត់ទៅនៅចាំថ្នាក់ពួក រដ្ឋសភាក៏ដូច....

ឡាយុំៈ ដូចសភាយើងសព្វថ្ងៃ?

សម្បត្តិៈ ហ្នឹងដូចសភាយើងសព្វថ្ងៃ ។

ឡាយុំៈ ប្រធានក្រុមប្រឹក្សាស្រុកអីចឹង?

សម្បត្តិៈ ហ្នឹងហើយអីចុះឯងតាមមើល ចុះទៅចាំនៅនោះ ។

ឡាយុំៈ មានយោធា មានស៊ីវិញ អីចឹងកាលហ្នឹង មានទទួលនយោបាយ...

វណ្ណៈ ចុះពូកាលទទួលបញ្ជាហ្នឹងជាលាយលក្ខ័អក្សរទៅ ឬគ្រាន់តែប្រាប់តាមមាត់ទេ?

សម្បត្តិៈ លាយលក្ខ័អក្សរគេសរសេរឲ្យមកឈ្មោះណាៗត្រូវធ្វើម៉េចៗអី គេសរសេរមក ត្រូវដោះឈ្មោះនេះ ។

វណ្ណៈ អីចឹងមានដោះលែងដែរ?

សម្បត្តិៈ អូ! ដែលមានដោះលែងទេ មានតែយកទៅវៃចោល និងបញ្ជូនមកណេះ ។

វណ្ណៈ	អត់មានដោះលែងទេអីចឹង?

សម្បត្តិៈ	អត់មានទេ! ដោះលែងអត់មានសោះ ។

ដានីៈ	ពួអត់ដែលមានដោះលែង ដូចថាឃើញអ្នកទោសហ្នុងអាណិត...

សម្បត្តិៈ	មានរួចម្តង៣នាក់ ។

ដានីៈ	យ៉ាំងម៉េចរួចហ្នឹង?

សម្បត្តិៈ	៣នាក់រត់បាត់ គេរករឿងដែរ គេប្រជុំធ្វើការទិតៀន គេរករឿងខ្ញុំដែរ ។

ដានីៈ	រួចហ្នុងមិនមែនបំណងពួអ្នកដោះលែងទេ គេលួចរត់ខ្លួនឯងទេ!

សម្បត្តិៈ	បាទ! រត់រួច ទាញខ្នោះ ដាក់រ៉ូស៊ីបាន ដកជើងរួច ហែកពន្ធាលួសឯលើនោះ ។

ដានីៈ	ទៅបាត់៣នាក់?

សម្បត្តិៈ	៣នាក់ ។

ដានីៈ	ទៅគេរករឿងពួ?

សម្បត្តិៈ	រករឿងខ្ញុំដែរ រកដាក់គុកដាក់អីឯណាឯណី រកវ៉ៃចោលដែរណាកាលណុះ ដល់នេះប៉ុន ប៊ិ យន អូ!អត់ទេ ប៊ិ ណា ទេជួយនិយាយ វាមិនសូវស្គាល់រចនាសម្ព័ន្ធដូចសព្វថ្ងៃ ។

ដានីៈ	ចុះកាលហ្នុងយើងធ្វើការអីជាមួយខាងស្រុក ខាងគណៈស្រុក ខាងសន្តិសុខ ខាងយោធាស្រុកអី?

សម្បត្តិៈ	អត់ដែលទៅទេ អត់ដែលទៅចូលរួមប្រជុំជាមួយ គេមិនដែលហៅយើង នៅតែខ្ញុំនៅយាមឃ្នាំងអី គេមិនដែលពួ ដែលហៅដែលអីទេ មិនដែលពួហៅថា ទៅប្រជុំអីចេះមួយអីចុះមួយមិនដែលទេ កាលនោះបាយទឹកដូចជាខ្សត់ខ្សោយខ្លះហើយខ្ញុំ ដូចជាខ្វន់ហើមខ្លះ ។

ដានីៈ	ចុះពួអ្នកដែលយើងត្រូវវ៉ៃចោលអី ពួមានដែលស្គាល់ឈ្មោះអីទេ?

សម្បត្តិៈ	អូ! មិនដែលស្គាល់ទេ មានតែក្នុងបញ្ជីនោះ ។

ដានីៈ	បើតាមពួបា៉នស្មានមើលម៉ាចន្លោះដែលកាន់នៅហ្នុងវ៉ៃចោលប្រហែលប៉ុន្មានទៅ?

សម្បត្តិៈ	២ឆ្នាំ! ប្រហែលខ្ទង់ជាង១០០នាក់ហើយ បើខាងត្បូងសាលាវិទ្យាល័យនោះប្រហែលខ្ទង់៥០ ប៉ុនវ៉ៃជំនាន់អាក្រោយខ្ញុំទៀតសម័យ ប៊ិ រាម នោះវ៉ៃច្រើនលើសខ្ញុំទៅទៀត ។

ដានីៈ	ប៊ិ រាម ហ្នុងគាត់ធ្វើអីគេ?

សម្បត្តិៈ	ប៊ិ រាម គាត់ធ្វើគណៈស្រុក ដកពីព្រះនេត្រព្រះមក ។

ដានីៈ	គណៈស្រុក!

សម្បត្តិៈ	ដកពីព្រះនេត្រព្រះមក ។

ដានី៖	ចុះពូគណៈស្រុកថ្មពួកដំបូង ឈ្មោះ ឆាត អីចឹង!

សម្បត្តិ៖	ឈ្មោះ ឆាត ។

ដានី៖	បន្ទាប់ពីឆាត មក?

សម្បត្តិ៖	ប៉ិ ឆាត, ប៉ិ រាម ហ្នឹងឯង ។

ដានី៖	ចុះឈ្មោះ រិទ្ធិ ឈ្មោះអីទៀត?

សម្បត្តិ៖	អូ! អត់ដឹងទេ ស្គាល់តែប៉ិឆាតនេះ សម័យខ្ញុំទៅត្រពាំងថ្ម ខ្ញុំមកពីយោធា ខ្ញុំទៅណុះទៅត្រពាំងថ្មបណ្ដោយ ក្ដាប់កម្លាំង ប៉ុនអត់មានគ្រោះថ្នាក់អីទេ មានតែនៅក្នុងសន្តិសុខហ្នឹងឯងពាក់ព័ន្ធអារឿងសម្លាប់មនុស្ស ។

ដានី៖	ចុះនៅក្នុងគុកហ្នឹង អ្នកទោសដែលគេចាប់មកហ្នឹង គេឲ្យហូបចុកយ៉ាងម៉េចទៅ?

សម្បត្តិ៖	ហូបបាយធម្មតា ម្ហូបស្ងោរត្រីអី ត្រីនៅនោះដើរបង់បាន មិនចំណាយប្រាក់លើកថ្នាក់អី ។

ឡាយុំ៖	អ្នកទោសនៅនោះគ្រាន់បើជាងប្រជាជន!

សម្បត្តិ៖	បាទ! អង្ករ បាយ អត់មានបបរទេ ។

ឡាយុំ៖	ប្រជាជនស៊ីបបរ ។

សម្បត្តិ៖	អត់មានបបរទេ សម័យនោះអត់ទាន់មានបបរទេ ។

ដានី៖	អ្នកទោសគេឲ្យបាយអីទៅ?

សម្បត្តិ៖	ហូបបាយ ហូបធម្មតា យ៉ាប់តែរឿងវ៉ៃចោលទេ ម្ហូបខ្ញុំប៉ុនណាហូបចុះឯង ព្រលិតគឺព្រលិតដូចគ្នា ត្រីឆ្នាំង១ដូចគ្នា ស្ងោរឆ្នាំងធំទៅ អីណុះ៦នាក់ទៅ យើង៨នាក់ទៅដាក់អាឆ្នាំងធំប៉ុណ្ណេះ ពងយើង កាលណុះចិញ្ចឹមទាផង កាលណុះប្រហែលជា១០០ក្បាល ដាងស៊ីពងទា អត់តែស្រាដឹក ។

ដានី៖	ចុះពូដូចថាយើងត្រូវធ្វើទារុណកម្មអី ដូចថាយើងត្រូវវ៉ៃ ។

សម្បត្តិ៖	អត់មានធ្វើទារុណកម្មអីទេ បើធ្វើទារុណកម្មអត់មានសោះ ចាប់តែយកទៅវ៉ៃចោល និងបញ្ជូនទៅថ្នាក់លើ អត់មានធ្វើទារុណកម្មគាប់អីណាណី អូ! បើសួរចម្លើយគេសួ គ្រាន់តែយើងដោះលែងឲ្យគេទៅ គេយកទៅសួរទៅ អាហ្នុងគេហ៊ុំកៅស៊ូ ហ៊ុំអី ឃើញដែរ ឃើញគេហ៊ុំកៅស៊ូហ៊ុំអី ។

ដានី៖	ចុះអ្នកសួរចំម្លើយហ្នឹងអត់នៅប្រចាំនៅ...

សម្បត្តិ៖	អត់ទេ! គេនៅឯណុះ ដល់ពេលគេមកសួរ ដូចថាឈ្មោះនោះត្រូវសួ គេបញ្ជា ពីនោះមកស្រេច គេមកដល់គ្រាន់តែប្រាប់យើងថា បងដោះឈ្មោះ ក ឬក៏ គ ២នេះឲ្យខ្ញុំ ខ្ញុំក៏ឲ្យ

ក្មេងៗដោះយកទៅ ចងទៅ យកទៅ គេនៅចាំបឹច សៀវភៅ គេណុះ គេសួយាំងម៉េច ខ្ញុំអត់បានដឹងទេ គេលាក់ការផ្ទៃក្នុងរបស់គេណា ខ្ញុំមើល ខ្វាចតែរូច ហើនិងលែងប៉ុណ្ណោះ ។

ឡាយុំៈ ខ្ទឹមសារសំខាន់ដែលគេសួច្រើនតែរឿងហ្នឹងឯងរឿងរត់ រឿងនិន្នាការ រឿងអីៗ...

សម្បត្តិៈ បាទ! មិនបានសួរផ្ទាល់ខ្លួនខ្ញុំទេ ។

ដានីៈ ពូអត់បានបានសួរទេ?

សម្បត្តិៈ អត់ទេ! គ្រាន់តែយាមកុំឲ្យតែរូច តែអីហ្នឹង

ឡាយុំៈ ហើទោសដែលគេចោទ គេអីហ្នុង ពូជឿថាវាមានអីចឹង ឬទោសដែលគេចោទម្នាក់កំហុស ដាក់គ្នាទេកាលណុះណា?

សម្បត្តិៈ មិនដែលមានរឿងអីណុះទេ ចុះគ្នារត់យកម៉ារូចខ្លួន សួយាំងម៉េចទៀតទៅ ខ្ញុំមិនដឹងសួរយាំង ម៉េចទៀតទេ ខ្ញុំគោលគំនិតរបស់ខ្ញុំមិនដឹងថាសួរយាំងម៉េច ចុះគ្នារត់នោះគឺរត់យកតែម៉ារូច ខ្លួនហ្នុង ។

ដានីៈ ចុះពូនៅកន្លែងយាមហ្នុងហូបបាយ ហូបអីធម្មតាអត់មានហូបបបរទេ?

សម្បត្តិៈ អត់ទេ! អត់មានបបរទេ បាយ ។

ដានីៈ មួយថ្ងៃ៣ពេល!

សម្បត្តិៈ មួយថ្ងៃ៣ពេល ។

ឡាយុំៈ អត់តែស្រាដឹក!

សម្បត្តិៈ អត់តែស្រាដឹកនោះឯង សាច់ខ្វះអីបើចិញ្ចឹម១០០ក្បាលដាងនោះ ។

ដានីៈ ចុះការងារក៏មិន យើងគ្រាន់តែយាមអ្នកទោសនិងយាមឃ្លាំងទេ?

សម្បត្តិៈ បាទ! អាចម៍នោមអីជូនមនុស្សជុះអាចម៍ ឬចេញមនុស្សឯណាណើអាហ្នឹងកូនក្មេងៗទេ ។

ដានីៈ ពូគ្រាន់តែអ្នកបញ្ជាទេ!

សម្បត្តិៈ គ្រាន់តែអ្នកបញ្ជាទេ ថាអូឃើជុះអាចម៍ហើយ ពីរនាក់ទៅ ថាមើលពួកហ្វែងមើលពួកនោះជុះ អាចម៍ផង នាំទៅជុះទៅ ។

ឡាយុំៈ គេធ្វើរបងលួសក្រាសដែរ!

សម្បត្តិៈ ទេ! កណ្តាលវាលស្រែ ជុះអាចម៍កណ្តាលវាលស្រែបាំងភ្លឺ ។

ឡាយុំៈ អត់ទេ! គុកហ្នឹងណា?

សម្បត្តិៈ អូ! គុកហ្នុងរបងលួស ព័ទ្ធពីលើ ចំហៀងអីចេះ ។

ដានីៈ ពេលនាំទៅបត់ជើង បត់អីហ្នឹង មានអ្នកទោសរត់អីមានសម្ភាពហ្នឹងដែរអត់?

សម្បត្តិៈ មិនដែរទេ! ជុះអាចម៍មិនដែលរត់ផង គ្រាន់តែលួចរត់៣នាក់ម្តងហ្នុង ។

ដានីៈ អ្នកទោស៣នាក់លួចរត់ហ្នុងឆ្នាំណា អ្នកទោស៣នាក់លួចរត់ហ្នុង?

សម្បត្តិៈ ឆ្នាំ៧៧ ។

ដានីៈ ទោសប្រភេទម៉េចដែលអ្នកទោស៣នាក់ហ្នុងលួចរត់ហ្នុង?

សម្បត្តិៈ ទេដូចមិនមែនអ្នកថ្មពួកទេកាលណុះ អ្នកស្រុក អ្នកស្រែមិនមានមកពីនោះទេ ដូចថាអ្នកព្រះនេត្រព្រះមើលទៅកាលណុះ គេចាប់បានគេបញ្ជូនទៅនោះ ។

ដានីៈ ខុសអីគេ ៣នាក់ហ្នុង?

សម្បត្តិៈ ទេ! រត់ឆ្លងដែន ។

ឡាយុំៈ កាលនោះបែបច្រើន រត់ឆ្លងដែនទៅថៃ?

សម្បត្តិៈ ច្រើន! គ្រាន់តែចូលគុកហ្នឹង បើពួកអ្នកថ្មីមិនដែលរត់រួចមួយទេ ។

ឡាយុំៈ អត់ដឹងផ្លូវ!

សម្បត្តិៈ អត់ដឹងផ្លូវ! គ្នាមិនដែល ដូចយើងស្រុកស្រែអីចេះឯណា ដែលមានកម្លាំងកំហែងអីប៉ុន្មានរត់ទៅមានទៅរត់ដូចយើងអី ។

ដានីៈ សុទ្ធតែប្រុស ៣នាក់លហ្នឹង?

សម្បត្តិៈ ប្រុសទាំងអស់ គេចាប់អាមួយនោះសម្លាប់ប្រពន្ធខ្លួនឯង សម្លាប់ប្រពន្ធហើយរត់ យើងតាមចាប់បាន ។

ដានីៈ ក្នុង៣នាក់ហ្នឹងមានចាប់បានវិញទេ?

សម្បត្តិៈ អត់ទេ!

ឡាយុំៈ គុកហ្នឹងតាំងពីជំនាន់ពួកពាយ័ព្យមក ឬ?

សម្បត្តិៈ ពាយ័ព្យ ។

ឡាយុំៈ ពួកនិរតីគេយកតាំងហ្នឹងដដែល?

សម្បត្តិៈ បាទ! គេយកទីតាំងដដែល គុកមានតែមួយហ្នឹង ។

ដានីៈ ដល់ឆ្នាំ៧៧ ពូផ្លាស?

សម្បត្តិៈ នៅទៅធ្លកវិញ ។

ដានីៈ ទៅនៅឯណាវិញ?

សម្បត្តិៈ ទៅតាមវរៈឈ្មោះខ្ញុំនៅឯណុះនោឯធ្លកណុះ កងនៅឯណុះ កងតូចនៅណុះ ។

ដានីៈ ម៉េចបានគេផ្លាស់ពូទៅណុះ?

សម្បត្តិៈ កាលនោះគេរំសាយហើយ កាំភ្លើងអីគេដឹកមកស្វាយនេះអស់ហើយ អាកន្ទែនគុកនោះក៏គេរំលាយចោលអស់ គេឲ្យទៅនៅការពារណុះវិញ នៅឆ្នុកណុះ។

ដានីៈ កាលហ្នឹងពួកនិរតីមកនៅ?

សម្បត្តិៈ មកហើយ មកខ្លះហើយ ទៅនៅឯណុះបានមិនដល់មួយឆ្នាំទេ គេហៅខ្ញុំមកក្តាប់ចល័តនៅមេបុណ្យ។ កាលនៅមេបុណ្យ ខ្ញុំនៅគ៦ ប្រធានគ ប៉ុនអត់មានអីទេ អ្នកស្រុក អ្នកស្រែហ្នឹង។

ដានីៈ ចល័តប៉ុន្មានទៅ មាំ គ ប៉ុន្មាននាក់ទៅ?

សម្បត្តិៈ មាំ គ ហ្នឹង១០០នាក់ ដកស្ទូងហ្នឹងឯង។

ដានីៈ ពីឆ្នាំណាដល់ឆ្នាំណា?

សម្បត្តិៈ ៧៨ មិនដឹង។

ដានីៈ ហីម៉េចទៀតទៅ?

សម្បត្តិៈ ដកខ្ញុំពីនោះទៅ បានទៅនៅត្រពាំងថ្ម។

ដានីៈ មកត្រពាំងថ្មធ្វើអីទៀតទៅនៅត្រពាំងថ្ម?

សម្បត្តិៈ មកត្រពាំងថ្មលើកដីរែកដីហ្នឹងហើយ។

ដានីៈ កាលហ្នឹងពូនៅចល័តដដែល?

សម្បត្តិៈ នៅចល័ត ខ្ញុំនៅវងគេ វងនិរតីកាលហ្នឹង ខ្ញុំវងទី១ ផាន់ នោះនិរតី។

ឡាយុំៈ អាហ្នឹងជាប្រធានអីគេ?

សម្បត្តិៈ ប្រធានចល័តមាំស្រុកថ្មពួកយើងហ្នឹង។

ដានីៈ ប្រធានចល័តមាំស្រុកថ្មពួក?

សម្បត្តិៈ មាំស្រុកថ្មពួក។

ដានីៈ ហីពូ អនុ?

សម្បត្តិៈ អនុ! មេនោះឈ្មោះ ផាន់ បានខ្ញុំ ហីមានប៊ុ អ្នួននោះនៅវងខ្ញុំក្រោមខ្ញុំទៀត សង ស្រី មកពីនិរតីដែរក្រោមខ្ញុំទៀត។

ឡាយុំៈ ត្រួតមនុស្សប្រហែលប៉ុន្មានចល័តហ្នឹង?

សម្បត្តិៈ មនុស្សច្រើនដែរ រាប់រយ ប្រហែល២០០, ៣០០។

ឡាយុំៈ សុទ្ធពេញកម្លាំងហើយពួកហ្នឹង?

សម្បត្តិៈ ពេញ។

ឡាយុំ៖ ពេលពូទៅសួននៅមេបុណ្យ ហីទៅលើកនៅត្រពាំងថ្មហ្នឹង ទៅលើកដីហ្នឹង ពូហូបបាយ ឬហូបបបរ?

សម្បត្តិ៖ ហូបបាយ ។

ដានី៖ ពួកចល័តហូបបាយ ឬហូបបបរ?

សម្បត្តិ៖ ហូបបាយ អីចឹងរែកដីម៉េចរួច រែកដីសុទ្ធម៉ែត្រគីប ឡើងត្រពាំងថ្ម ឡើងទំនប់ផង ។

ដានី៖ អីចឹងពូនៅក្នុងកងចល័តហ្នឹងមានសុទ្ធតែយុវជនយុវនារីទាំងអស់ ឬក៏មានអ្នកដែលមានប្ដីមានប្រពន្ធដែរ?

សម្បត្តិ៖ មិនដែលមានទេ មានតែមេម៉ាយ ដូចគ្រូសុរិយា គ្រូសុរិយាទៅដែរតើ គ្មានបានធ្វើការងាររអីទេ បើក្រៅពីខ្ញុំ សម័យមុនគេវៃចោលបាត់ទៅហើយ បងអើយជួយខ្ញុំផង កាលហ្នឹងគាត់នៅបង្រៀនហ្នឹងគ្រូសុរិយា ។

ឡាយុំ៖ គាត់បង្រៀននៅសាលាណា?

សម្បត្តិ៖ គាត់បង្រៀននៅសាលាសង្គ្រោះនេះហើយអ្នកគ្រូសុរិយានេះ កាលនោះគាត់បានប្ដីហើយដឹងតែមិនដែលបានធ្វើការងាររអីទេ ។

ឡាយុំ៖ អ្នករបស់ CWCC នេះ?

សម្បត្តិ៖ បាទ!

ដានី៖ ឈ្មោះអ្នកគ្រូសុរិយា!

សម្បត្តិ៖ អ្នកគ្រូសុរិយា ។

ឡាយុំ៖ គាត់ធ្វើអីកាលហ្នឹង?

សម្បត្តិ៖ គាត់ទើបជម្លៀសមកនៅតាមវាលនេះ ទៅគេដាក់ឈ្មោះទៅ សួរគាត់ដឹងហើយ ខ្ញុំមិនដឹងធ្វើម៉េចទេ បើថាសម័យមុនវៃចោលហើយ ។

ដានី៖ សម័យមុនណា?

សម្បត្តិ៖ សម័យមុនខ្ញុំទៅហ្នឹង គេវៃចោលហើយ ឲ្យតែអសុដង់ ធ្វើការងារទន់ល្អិល្អក់អីចឹងនោះ ។

ឡាយុំ៖ គាត់ទន់?

សម្បត្តិ៖ គាត់ដូចថាទៅជាឈើ ហើយទន់ធ្វើអីមិនកើត ល្អិល្អក់ រែកមិនរួចទេ ថាចេះតែនៅទៅខំប្រឹងបន្តិចៗ ទៅគាត់ឈឺតែរហូត ។

វណ្ណៈ៖ ពូគាមដឹងខ្លះៗ ខាងនិរតីមកការវៃចោលគាត់តែមានកម្រិតខ្ពស់ហើយ?

សម្បត្តិ៖ អូ! ខ្ពស់ ។

វណ្ណៈ	អ្នកមានថានៈដូចជាពូអីចឹង ច្រើនតែពួកនិរតីចាប់បញ្ជូន ចាប់ខ្លួនពួកពាយ័ព្យហ្នឹងណា តាមខ្ញុំដឹង ចុះពូ ពួកនិរតីមើលឃើញគោលជំហរពូយ៉ាងម៉េចដែរបានគេទុកឲ្យ...

សម្បត្តិៈ	ដែលវ៉ៃខ្ញាំងនោះអីចេះ... អានោះខ្លាមផប្រធានសហករណ៍អីថានៈដូចខ្ញុំអីខ្ពស់ៗ ជំនួយការ ផារស្រុក កាលនោះវាមានរឿងជាមួយនេះទេ ខ្ញុំឲ្យចល័តស៊ីបាយឧទាហរណ៍ដូចថាគេឲ្យ១០ កំប៉ុង ១០ថ្ងៃអីចឹងណា ខ្ញុំថាហ្វែងដាក់ ៥ថ្ងៃអីទៅ ដាំឲ្យស៊ីឲ្យឆ្អែត វាបាត់អង្ករ តាំងថាខ្ញុំ យកទៅឲ្យខ្មាំងឲ្យអីឯណា ចេះតែរករឿងខ្ញុំណា យកទៅដល់កសាងខ្ញុំ ប៉ុ រាម ហ្នឹងឯងយក ទៅនោះ គេកំពុងវ៉ៃ គៀនៗផ្ទះនោះឯង គៀនផ្ទះទទួលភ្ញៀវ ខ្ញុំថាផាប់បានហើយ រាគមៅ រាគអាចម៍ គេសម្រុតដែរ ។

ដានីៈ	ពូខ្ញុំចង់ដឹងអីចេះដូចថានៅក្នុងកងចល័តហ្នុងយើងចាប់ផ្ដើមធ្វើការផារពីម៉ោងប៉ុន្មានដល់ម៉ោង ប៉ុន្មាន ហើពេលយប់យើងធ្វើអីទៀតណាពូកាលហ្នុង?

សម្បត្តិៈ	យប់មិនដែលប្រើទេ ពីព្រោះអីចេះឥទាហរណ៍ថាមួយថ្ងៃ៤ម៉ែត្រគីប បើអ្នកឯងរែកមួយ ម៉ោងរួច អ្នកឯងទៅរកអីរកចុះ កន្លះម៉ោងរួចក៏នេះទៅធ្វើរកអីរកចុះ ដេកយ៉ាងម៉េចក៏ដេក ទៅឲ្យតែរួច ថ្ងៃមិនធ្វើចាំធ្វើយប់ក៏បានឲ្យតែរួច៤ម៉ែត្រគីប អត់មានចាំថាដាក់ផែនការហើយ ធ្វើនោះ វាមានប្រធានវានោះ មេកងមេអីនោះ ។

ឡាយុំៈ	ដើរកត់ត្រា!

សម្បត្តិៈ	បាទ! ដើរអត់ត្រាថាអានេះរួចហើយបានប៉ុន្មានម៉ែត្រគីប ចង់ធ្វើយប់ក៏ធ្វើទៅ ថ្ងៃដើរកត្រី រកអីនោះ ទឹកស្អីងវាមានត្រីមានអីនោះ ។

ដានីៈ	ចុះពូ ក្នុងហ្នឹងម្នាក់ត្រូវតែរែកឲ្យរួច៤ម៉ែត្រគីប?

សម្បត្តិៈ	បាទ! ៤ម៉ែត្រគីបត្រូវតែរួច ។

ដានីៈ	ប៉ុន្តែភាគច្រើនអ្នកនៅហ្នុងរ៉ែករួចអត់៤ម៉ែត្រគីបក្នុងមួយថ្ងៃ?

សម្បត្តិៈ	វាខ្លះក៏ថ្ងៃធ្វើខ្លះទៅ យប់ធ្វើខ្លះទៅ ។

ដានីៈ	បើយើងគិតទៅ តាមធម្មតា៤ម៉ែត្រគីបច្រើនឬតិចសម្រាប់មនុស្សម្នាក់រែកក្នុងមួយថ្ងៃ?

សម្បត្តិៈ	បើថាអ្នកកម្លាំងគឺថាមិនច្រើនទេ គេរែកមួយភ្លែតហ្នុងឯង តែបើអ្នកទន់ខ្សោយយ៉ាប់គ្រាន់ ដែរ ៤ម៉ែត្រ ។

ឡាយុំៈ	បើឥឡូវ ពូគិតឥឡូវវិញទៅរួចទេ បើសិនឥឡូវនេះទៅរួចអត់?

សម្បត្តិៈ	ទេ! ទៅមិនរួចទេ ។

ដានីៈ	ទាំងនារី បុរស ៤ម៉ែត្រគីបស្មើគ្នា ឬក៏ខុសគ្នា?

សម្បត្តិៈ ទេ! ដាក់ផែនការស្មើរគ្នាហ្នឹង។

ដានីៈ នារីក៏៤ម៉ែត្រគីប បុរសក៏៤ម៉ែត្រគីបស្មើគ្នា!

សម្បត្តិៈ បាទ! ស្មើរគ្នា។

ដានីៈ ចុះពូអត់មានគិតថាបុរសខ្លាំងជាង ធ្វើការធ្ងន់ជាងនារីអី គេអត់គិតទេកាលពីសម័យហ្នុង?

សម្បត្តិៈ ស្រីៗមានមិនរួចដែរតើស ប៉ុនយើងគ្រាន់តែកសាងណែនាំអប់រំទៅ។

ដានីៈ ចុះកាលជំនាន់ហ្នុងខាងប្រធានក្រុមប្រធានកងគេរាយការណ៍មកថាអ្នកនេះធ្វើការអត់រួច អ្នកនេះខ្ជិល អ្នកនេះមានទិន្នាការគេមានដែររាយការណ៍អីចឹងមកពូទេ?

សម្បត្តិៈ គេមិនរាយទេ គេរាយតែចំនួន បានចំនួនប៉ុន្មាន គេចាំទទួល ខ្ញុំគ្រាន់តែគ្រប់គ្រងដើរមើល ការងារខុសត្រូវអី បើអាខាងម៉ែត្រគីប ខាងស្ថិតិគេ គេទទួលខាងវាស់វែងអីណា ពាក់ពន្ធនឹងលោក ពាន់ ហ្នឹងឯង។

ដានីៈ ពីណាគេ?

សម្បត្តិៈ ពាន់ សព្វថ្ងៃធ្វើគ្រូបង្រៀន។

ឡាយុំៈ ប៉េង ពាន់។ ប៉េង ពាន់ គាត់ទទួលខាងអី?

សម្បត្តិៈ គាត់ទទួលខាងស្ថិតិ ទទួលខាងលទ្ធផលដែលធ្វើបានប៉ុន្មានៗ។

ដានីៈ ផែនការដែលគេដាក់មកហ្នុង គេដាក់មកពីខាងណាដាក់ទិសមកពូ ឬក៏ពូជាអ្នកចេញផែនការ?

សម្បត្តិៈ អត់ទេ! ទទួលផែនការ មកប្រជុំ តំបន់ហ្នឹងឯង។

ដានីៈ មកប្រជុំ!

សម្បត្តិៈ មកប្រជុំនៅស្ពានលេខមួយ កន្លែងត្រង់នោះមាន សាលប្រជុំ ផ្ទះប្រជុំមួយ។

ដានីៈ ពីណាគេមកដឹកនាំប្រជុំហ្នឹង?

សម្បត្តិៈ មិនដឹងអ្នកណាទេ។

ឡាយុំៈ ប្រជុំយូៗឬពូ?

សម្បត្តិៈ យូៗគ្រាន់ដែរ ទទួលផែនការ ដាក់ផែនការ។

ឡាយុំៈ និយាយដដែលៗតាមមើល?

សម្បត្តិៈ ដដែលៗហ្នុង។

ឡាយុំៈ ប៉ុនអត់មានអ្នកណាហ៊ានទេ ស្ងាត់ឈឹងន៎!

សម្បត្តិៈ បាទ! ទទួលផែនការ ហើយយើងទៅដាក់ផែនការតទៀតទៅណា...

ដានី៖ ពាម ដែលពូមានប្រសាសន៍មិញហ្នឹងក៏គាត់មកប្រជុំដែរ?

សម្បត្តិ៖ មកប្រជុំដែរតើស ប៉ុ ផល មួយទៀត ។

ដានី៖ ចុះកាលហ្នុងស្គាល់យាយថែមទេកាលហ្នុង?

សម្បត្តិ៖ យាយថែមស្គាល់តើស យាយថែមព្រះនេត្រព្រះ ។

ដានី៖ យាយថែមគាត់ធ្វើអីទៅ?

សម្បត្តិ៖ នៅខាងស្រុកដែរ ប៉ុនមិនដឹងធ្វើខាងអី ។

ដានី៖ គាត់មកប្រជុំដែរ?

សម្បត្តិ៖ មកប្រជុំ តួនាទី គេមិនសូវដែរប្រកាសទេ ។

ដានី៖ អ្នកដឹកនាំប្រជុំពីណាគេពូចាំទេ អ្នកដែលធំជាងគេ អ្នកដែលដឹកនាំប្រជុំ?

សម្បត្តិ៖ ទៅពីតំបន់ហ្នឹងឯង ទៅពីស្វាយហ្នឹងទៅ ។

ដានី៖ ពីណាគេហ្នឹង?

សម្បត្តិ៖ អត់ដឹងផង! ភ្លេចឈ្មោះមនុស្សទៅប្រជុំបាត់ហើយ ។

ឡាយុំ៖ អ្នកធំជំនាន់ហ្នុងទៅណាមកណាជិះអីពូ ដើរ ឬក៏ជិះសេះ?

សម្បត្តិ៖ ទេ! ឡាន ។

ឡាយុំ៖ អ្នកធំមែនទែនគេជិះឡាន!

សម្បត្តិ៖ មានឡានតើស ។

ដានី៖ ពូជិះអីទៅកាលហ្នុង?

សម្បត្តិ៖ ដើរ! ដែលមានម៉ូតូមានអីជិះទេ ។

ដានី៖ អត់មានម៉ូតូជិះទេ!

សម្បត្តិ៖ អត់ទេ!

ឡាយុំ៖ អារម្មណ៍អ្នកធំកាលនោះម៉េចដែរ អារម្មណ៍យើងឃើញរាងសង្ហា..?

សម្បត្តិ៖ ទេ! គ្មានឃើញសង្ហាអីទេ ។

ឡាយុំ៖ គ្រាន់បើជាងប្រជាជន?

សម្បត្តិ៖ មានតែភ័យ រឿងបញ្ហាអីកើតឡើងមកយើងនេះឯង ខ្ញុំមិនដូចគេទេ គិតអីចុះទៅវិញ គ្រាន់តែចល័តរត់តិចតួច វាមិនសូវអី មិនសូវមានបន្ទុករឿងអី ។

ដានី៖ ពូកាលជំនាន់ពូមកក្តាប់ អត់មានត្រូវចាប់អីត្រូវវ៉ៃចោលអី ឬចាប់យកទៅដាក់គុកអីមានទៀតដែរអត់ ជំនាន់ពូមកក្តាប់នៅត្រពាំងថ្ម?

សម្បត្តិៈ មិនដែលមានទេ! មានផាប់ដោយលង់ទឹកមួយ ។

ដានីៈ ផាប់ដោយលង់ទឹកឬ?

សម្បត្តិៈ អ្នកនៅតាសៀវ ស្រី ។

ដានីៈ ចុះម៉េចបានមកដល់ជំនាន់ពូហ្នឹងលែងចាប់ លែងវៃចោលទៀត?

សម្បត្តិៈ អានោះវាជំហានទី២ ដែលគេលើក គេធ្វើទំនប់បានខ្លះហើយ អានេះយើងបន្ថែមឲ្យខ្ពស់ទៅលើទៀត ។

ដានីៈ ចុះអាជំហានទី១ ម៉េច?

សម្បត្តិៈ អូ! អានោះវៃចោល អាប៉ិ រ៉េង ផង សម័យអាប៉ិ រ៉េង វៃចោលចំណាប់ណាស់ កាលនោះខ្ញុំនៅយោធាអាឡើយទេ មិនសូវដឹងរឿងថាផ្ទៃក្នុងគេអាម៉េចៗសម្រាប់អីប៉ុន្មានៗ ប៉ុនគេនិយាយតាមសហករណ៍គេនិយាយនោះ សម្លាប់ច្រើនដែរ ។

ដានីៈ ចុះពូអាជំហ៊ានទី១ ពីឆ្នាំណាដល់ឆ្នាំណា ហើជំហ៊ានទីពីរពីឆ្នាំណា?

សម្បត្តិៈ ពីឆ្នាំ៧៦, ៧៧ ពីឆ្នាំ៧៥, ៧៦, ៧៧ ។

ដានីៈ ចុះជំហ៊ានទី២របស់ពូពីឆ្នាំណាដល់ឆ្នាំណា?

សម្បត្តិៈ ក្នុងឆ្នាំ៧៦, ៧៧ ដែរ ។

ដានីៈ ពូនៅត្រពាំងថ្មដល់ណា ដល់បែកយួនចូលឬក៏...

សម្បត្តិៈ ដល់ខ្ញុំមកវិញ វាគ្រប់ដែនការហើយ ដល់ស្ពានស្រែងណុះ បានរំសាយចល័តមកវិញមកវិញ អត់មានធ្វើអីទេមកនៅក្តាប់ចល័តស្រុក មករង់គេ មករង់ប៉ិ សួត រឿងកាលនោះឯង អារឿងរកសម្លាប់ខ្ញុំចោលនោះ ថាខ្ញុំយកអង្ករឲ្យខ្មាំងហីណា វាបាត់ង់ង្ករគេកាលហ្នុងខ្ញុំយ៉ាប់ហើយ ខ្ញុំហើម ស៊ីមិនដែលឆ្អែត ស៊ីតែបបរ ស៊ីកាវែន វៃតែកូនកង្កែបស៊ី យ៉ាប់មែនទែន ។

ដានីៈ ឆ្នាំណាដែលគេរំសាយចល័តនៅត្រពាំងថ្ម ហើពូឡប់មកនេះ?

សម្បត្តិៈ ដើមឆ្នាំ៧៨ហើយ ។

ដានីៈ ៧៨ ហ្នឹងពូមកថ្មពួកវិញហើយ?

សម្បត្តិៈ បាទ!

ដានីៈ មកហ្នឹងពូនៅតែធ្វើអនុប្រធានចល័តស្រុកថ្មពួកដដែល?

សម្បត្តិៈ បាទ! អនុប្រធានកងចល័តស្រុក ។

ដានីៈ ឈ្មោះ សួត គាត់ប្រធាន?

សម្បត្តិៈ បាទ! ប្រធាន ។

ដានីៈ គាត់អ្នកនិរតី?

សម្បត្តិៈ ទេ! នៅភូមិស្វាយនេះឯង សព្វថ្ងៃនេះវានៅយ៉ក អំពិល ពង់ទឹក អានោះឯងវាប្ដឹងអាប៊ុ រាម ឲ្យយកខ្ញុំទៅវៃចោល វាកុងកាច់ខ្វាចខ្ញុំឡើងប្រធានឡើងអីណា ហីខ្ញុំទៅមានចិត្តអីចុះ នោះ មិត្តភក្តិពួកម៉ាក វាយោធាដូចគ្នាដែរនោះ ។

ដានីៈ ឈ្មោះអីសួត?

សម្បត្តិៈ សៅ សួត ។

ដានីៈ សៅ សួត សព្វថ្ងៃគាត់នៅឯណា?

សម្បត្តិៈ នៅភូមិយ៉ក ស្រុកអំពិលណុះ ។

ដានីៈ ឃុំអីគេ?

សម្បត្តិៈ ឃុំអំពិល ស្រុកអំពិលនោះឯង ។

ដានីៈ ស្រុកបន្ទាយអំពិល?

សម្បត្តិៈ ហ្នឹងហើយ ។

ឡាយុំៈ ឃុំអំពិល ស្រុកបន្ទាយអំពិល ។

សម្បត្តិៈ កាលនោះវៃពួកសហករណ៍ វៃពួកអ្នកខុសៗច្រើនណាស់ ខ្ញុំបានតែទៅហ្នឹងគេប៉ុណ្ណុះឯង កុំបានប៊ុ យន់តើស ប៊ុ យន់ ថាកុំ កុំទៅវៃវា មិនបានទេអាគាត់នេះនៅណុះ ល្អណាស់ ធ្វើល្អអីចេះមួយៗណា បានប៊ុ រាម ថាអូអីចឹង បានរួចខ្លួន ។

ដានីៈ ប៊ុ យន់ ធ្វើអី?

សម្បត្តិៈ ប៊ុ យន់ ខាងបូព៌ា គាត់ទៅមុននិរតី ទៅមុនប៊ុ រាម ហ្នឹង ទៅនៅក្តាប់ស្រុកមុន ប៊ុ រាម ហីកាលនៅត្រពាំងថ្មនោះ ប៊ុ យន់ ស៊ើបដឹងថាខ្ញុំមើលខុសត្រូវការងារចល័តអីបានល្អទៅក៏គាត់ស្រឡាញ់ណា ។

ដានីៈ ដល់ពេល រាម មក គាត់ធ្វើប្រធាន យន់ ហ្នឹងទៀត?

សម្បត្តិៈ ហ្នឹងហើយធ្វើប្រធាន យន់ នៅពេល ប៊ុ យន់ ទៅធ្វើប្រជុំ តាមគោករមៀត តាមអីទៅ គេរករឿងខ្ញុំគេប្រុងសម្លាប់ខ្ញុំចោល ។

ដានីៈ យន់ ឃើញពូធ្លាប់ដឹកនាំល្អនៅត្រពាំងថ្មក៏ជួយការពារពូ!

សម្បត្តិៈ បាទ! ថាកុំសម្លាប់វា មនុស្សល្អ ។

ដានីៈ ហើយម៉េចទៀតទៅ?

សម្បត្តិៈ រួចទៅខ្ញុំធ្វើស្រែធម្មតាក្តាប់មើលចល័តមើលអី ដកស្ទូង។

ដានីៈ នៅតែអនុប្រធានដដែល?

សម្បត្តិៈ អនុប្រធានដដែល អាហ្នឹងវាកាច់កុង អាមិស្ទូត ថាខ្ញុំចង់ធ្វើប្រធានធ្វើអី អូ!ខ្ញុំគ្មានចិត្តទេ។

ដានីៈ ឈ្មោះ ស៊ុន ឬ ឈ្មោះ ស្ទូត?

សម្បត្តិៈ ឈ្មោះ ស្ទូត សព្វថ្ងៃស្លាប់អស់។

ដានីៈ ចុះឈ្មោះ យន់ ហ្នឹងគាត់នៅរហូតដែរឬយ៉ាងម៉េច?

សម្បត្តិៈ ប៉ុ យន់ មិនដឹងគេយកទៅសម្លាប់ពេលណាទេ អត់ដឹងទេ។

ដានីៈ តែ រាម គាត់គ្រប់គ្រងនៅហ្នឹងរហូតដល់បែក?

សម្បត្តិៈ គ្រប់គ្រងអភិបាលស្រុករហូតដល់យួនចូល។

ដានីៈ ចុះនៅធ្វើអនុចល័តស្រុកថ្មពួកនេះរហូតដល់យួនចូលដែរ?

សម្បត្តិៈ ដល់យួនចូល ខ្ញុំរត់មកស្វាយចេកណោះ មកភូមិកំណើតវិញ បានរទេះមួយគ្រឿង។

ដានីៈ ចុះពូ ដូចពូធ្លាប់ធ្វើការងារអីចឹង ដល់យួនចូលមក ប្រជាជនគេអត់ទោមស្សន៍អី ជាមួយពូទេ?

សម្បត្តិៈ អត់ទេ! មិនដែលមានប៉ះពាល់អីផងអ្នកស្រុកអ្នកភូមិ ពេលណុះយើងមិនដែលបានធ្វើផ្ទាល់ដៃ វ៉ៃផ្ទាល់ដៃ ស្រែកគំរាមកំហែងគេ ដើរសំឡុតគេ បាញ់ចោះអីណា ខ្ញុំមិនដែលមានទេ។

ដានីៈ នៅស្វាយចេកហ្នឹង?

សម្បត្តិៈ ទាំងស្វាយចេក ទាំងណុះដូចគ្នា ចៅហ្វាយស្រុក ចៅហ្វាយអីស្គាល់តើស ស្គាល់ខ្ញុំ ទៅមកហ្នឹងបាយទឹកលិចកើត ប៉ុ យ៉ាន់ ប៉ុអីហ្នឹង សំគាល់មើលថ្មពួកក៏ដូចគ្នា សព្វថ្ងៃទៅ ខ្ញុំមិនដែលទៅវ៉ៃអ្នកណាផង សំឡុតអ្នកណាផង អ្នកភូមិ ដូចខ្ញុំថាអីចឹង ខ្ញុំឃាមឃ្វាំង ហ៊ីនិងឃាមគុកឲ្យគេ បទបញ្ជានៅលើគេ សួរចម្លើយ វ៉ៃសម្លាប់អីនៅលើគេទាំងអស់ ខ្ញុំគ្រាន់តែមើលថាបាត់រួចប៉ុណ្ណោះឯង គេវ៉ៃគេជាអីអានោះកម្លាំងរបស់គេវ៉ៃ យកកម្លាំងពីណាមានស្រីប្រុសណា មីស្រីៗចង់វ៉ៃដែរណា កុំនិយាយលេង។

ដានីៈ ស្រីចង់វ៉ៃដែរ?

សម្បត្តិៈ ហ្នឹងហើយ! ស្រីៗថាត្រូវវ៉ៃប៉ុន្មានៗ មកពីភូមិភាគ ពួកមីក្អួង មីលាវ។

ដានីៈ ក្អួង នៅឯណា?

សម្បត្តិៈ មីក្អួង នៅខេត្តសៀមរាប នៅរំដេង ធ្នក។

ដានី៖ នៅរស់ដល់សព្វថ្ងៃ?

សម្បត្តិ៖ នៅរស់តើស! មីនោះអនុប្រធាននារីសេនាជន ។

ដានី៖ ក្មេង ហ្នឹងអនុប្រធាននារី?

សម្បត្តិ៖ អនុប្រធាននារី ។

ដានី៖ អនុប្រធាននារីស្រុក?

សម្បត្តិ៖ អនុប្រធាននារីសេនាជនតំបន់ ។

ដានី៖ តំបន់ប៉ុន្មានហ្នឹង?

សម្បត្តិ៖ តំបន់៥ ហ្នឹង ។

ដានី៖ ឈ្មោះអី ឈ្មោះ អេង!

សម្បត្តិ៖ ឈ្មោះ អេង ។

វណ្ណៈ៖ ឥឡូវគាត់ធ្វើអី?

សម្បត្តិ៖ ទេ! ធ្វើស្រែធម្មតា ។

ដានី៖ គាត់នៅភូមិអីពូស្គាល់ភូមិគាត់ទេ?

សម្បត្តិ៖ ភូមិរំដេង គួយ តើសយាយប៉ិហ្នឹង ។

ដានី៖ ជនជាតិគួយឬ?

សម្បត្តិ៖ ហ្នឹងហើយ សក់វាក្ងីអស់ទាស់ហើយ ។

ដានី៖ ឃុំអីគេហ្នុង?

សម្បត្តិ៖ ឃុំត្រាំសសរ ក៏មិនដឹង លេងស្មាច់ ។

ដានី៖ ស្រុកអីគេហ្នុង?

សម្បត្តិ៖ ស្រុកស្រីស្នំ ។

ដានី៖ ខេត្តសៀមរាប ។

សម្បត្តិ៖ មីហ្នុងវាឈនៅម្នាក់ក៏វានៅដែរ?

ដានី៖ ចុះអេង កាលហ្នុងគាត់មានប្ដីអីនៅ?

សម្បត្តិ៖ អត់ទេ! អត់ទាន់មានទេ ។

វណ្ណៈ៖ ចុះឥឡូវប្ដីគាត់ ស្គាល់ឈ្មោះប្ដីគាត់សព្វថ្ងៃ?

សម្បត្តិ៖ មិនដែលដឹងទេ បែកគ្នាតាំងពីកាលណុះ ។

ដានី៖ ចុះម៉េចដឹងថាគាត់នៅភូមិរំដេង?

សម្បត្តិៈ ដឹងតើស ជីវប្រវត្តិវា ។

ដានីៈ ស្គាល់ឪពុកម្ដាយគាត់ទេ?

សម្បត្តិៈ មិនដែលស្គាល់ទេ ។ សួរថា មីក្មេង មានតែមួយប៉ុណ្ណឹងឯងនៅរំដេងនោះ ។

ដានីៈ រំដេងហ្នឹងមានតែអេង តែមួយហ្នឹងទេ?

សម្បត្តិៈ តែមួយ ប៉ុណ្ណឹងឯង ។

ដានីៈ ចុះពីណាទៀតដែលគាត់ជានារីៗ?

សម្បត្តិៈ មិនដែលមានទេ តែមីនោះស្គាល់ច្បាស់ ច្រើនតែបាត់ដំបង ពោធិ៍សាត់អីណាណី ។

ដានីៈ ចុះខាងនិរតីអ្នកដែលគាត់ធ្វើការធំៗខាងសន្តិសុខ ខាងអី ពូមានស្គាល់គាត់ទេ ក្រោយៗមកទៀតណា?

សម្បត្តិៈ មិនដែលមានផង ។

ដានីៈ ក្រោយៗពូទៀតដែលមកក្ដាប់មកកាន់នៅគុកនៅអី?

សម្បត្តិៈ ម៉ាសេរីពួកតាម៉េត តាអី កាលនោះវ៉ៃច្រើនណាស់ វ៉ៃច្រើនប៉ុ រាម ហ្នឹងឯង សេរីប៉ុ រាម ហ្នឹង ក្រោយខ្ញុំ ប៉ុរាមហ្នឹងវ៉ៃច្រើនណាស់ ប្រធានសហករណ៍អីអាណាកាច់កុងគ្នាអីម៉េចៗធ្វើជីវប្រវត្តិខុសរឿងអីម៉េចគេដកយកទៅវ៉ៃបណ្ដោយ ។

ដានីៈ ចុះពូដល់ពេលក្រោយមក ដល់ពេលយួនចូលមក ដល់ពេលពូមកស្វាយចេកហើយ ពូមានធ្វើអីតទៅទៀតដែរ?

សម្បត្តិៈ អត់ទេធ្វើស្រែធម្មតា ។

ដានីៈ ធ្វើស្រែ!

សម្បត្តិៈ ខ្ញុំទៅនៅភូមិត្រាំសសរ ស្រីស្នំខេត្តសៀមរាប គេរើសឲ្យចូលនគបាលដែរ កាលណុះសេរីដើមសម័យដើម ធ្វើនគបាលមិនតូចណាខ្ញុំ ប៉ុនប្រពន្ធចេះតែថា ម៉ែឪចេះតែថាហ្វែងមិនបាច់ធ្វើអីទេ ..ឆាប់គេស្អប់អីណាអីណី វៀតណាមវាកើសកាលនោះ ។

ដានីៈ ពេល៧៩ហ្នឹងពេលវៀតណាមចូលមក ជ្រើសរើសឲ្យពូចូលធ្វើនគបាលទៅ?

សម្បត្តិៈ ជ្រើសរើសឲ្យធ្វើនគបាល ធ្វើមេនគបាលទៀតសម័យនោះ ។

ដានីៈ នៅត្រាំសសរ?

សម្បត្តិៈ នៅភូមិពង្រ ឃុំត្រាំសសរ ។

ដានីៈ ចុះម៉េចបានពូទៅដល់ហ្នឹង?

ឡាយឃុំៈ ....ជំនួសនគបាល យកសេនាជនវិញ គណៈឃុំ...

សម្បត្តិៈ វៀតណាមវាមករើសផ្ទាល់កាលហ្នុងជំនាញការវា ប្រពន្ធ ម៉ែឪអីចេះតែថា...

ដានីៈ ត្រាំសសរឆ្ងាយពីភូមិកំណើតពូឬ?

សម្បត្តិៈ ត្រាំសសរចេញពីវៀនទៅ ចេញពីកំពីងពួយទៅ ឆ្លងទៅរំដេង ឆ្លងពីរូងទៅរំដេងហើយ ។

ដានីៈ ម៉េចទៀតទៅ ពូបានទៅធ្វើនគបាលហ្នុងពូបានទៅធ្វើទេ?

សម្បត្តិៈ អត់បានទៅធ្វើទេ! ប្រពន្ធថាឲ្យសម្រាកទៅ ម៉ែក្មេកអីថាឲ្យសម្រាកទៅ សម្រាករហូតដល់ ៨០ បានខ្ញុំចូលធ្វើទាហាន វរៈសេនាធំព្រំដែន ។

ឡាយុំៈ ចុះឥឡូវនេះ?

សម្បត្តិៈ សព្វថ្ងៃនេះរងជីបេ រងយោធាខេត្ត បន្ទាប់ពី...

ឡាយុំៈ ប្រធាននៅព្រះនេត្រព្រះ!

សម្បត្តិៈ អូ! តូច រិត នៅក្រុមប្រឹក្សាស្រុក គេប្រធាន...គេក្រុមប្រឹក្សាស្រុកហើយ ប្រាក់ខែគេជាន់ហើយ ប្រាក់តែណុះផង ប្រាក់ខែយោធាផង ។

ឡាយុំៈ ពូមិនមែនអានៅស្នាក់ការអូរអំបិលទេអីចុង?

សម្បត្តិៈ នោះខាងជីបេដើងគោក ។

ឡាយុំៈ ពូឥឡូវនេះរង...

សម្បត្តិៈ រងការិយាល័យទី២ ។

ឡាយុំៈ យោធាខេត្ត!

សម្បត្តិៈ យោធាខេត្ត ។

ដានីៈ ពូកាលពូទៅធ្វើឆ្នាំ៨០ ពូទៅធ្វើនៅវរៈព្រំដែន?

សម្បត្តិៈ បាទ!

ដានីៈ វរៈនៅក្នុងកងពលអីដែរ វរៈហ្នុង?

សម្បត្តិៈ កាលនោះវរៈដូចឯករាជ្យ ដូចបើកលុយបើកកាក់ពីក្រសួងមកបណ្តោយ វរៈសេនាធំព្រំដែនគេហៅអីចឹង ។

ដានីៈ ពីណាគេប្រធានកាលហ្នុង?

សម្បត្តិៈ អ៊ិន អើយ ប៉ូលីសសព្វថ្ងៃ ។

ឡាយុំៈ អូ! អ៊ិន អើយ ហ្នឹងធំផងអីចឹង?

សម្បត្តិៈ ដល់ពេលនេះទៅ ចូលខាងប៉ារ៉ា ស៊ីលុយស៊ីកាក់លិចកើតទៅ...

ដានីៈ ពូនៅព្រំដែនរហូតដល់ពេលណា បានមកនៅខេត្តវិញ?

សម្បត្តិៈ ខ្ញុំនៅព្រៃវែងមួយឆ្នាំ ពីឆ្នាំ រហូតដល់វៀតណាមវាយបែកហ្នឹងឯង វៀតណាមវាយបែកកាលណុះដល់ភ្នំពេញក៏មកនៅ ណោះបណ្តោយទៅ មកចូលដីបេងជើងគោកហ្នឹងកន្ទែងអាដន ពីដើមម៉េចវាភ្ជាក់ផ្សារ...

ឡាយុំៈ បងម្នាក់មិញធ្វើភ្នាក់ផ្សារជាមួយពូដែរ?

សម្បត្តិៈ ទេ! អានេះកម្ពុជាក្រោម អានេះវានៅកងពល៥១ ផ្ទះវានៅខាងមុខនោះ ។

ដានីៈ ចុះពូរៀបការឆ្នាំណា?

សម្បត្តិៈ ការកាល៨៩មិនដឹង ។

ដានីៈ ទើបរៀបការដែរ?

សម្បត្តិៈ ចាប់ដៃ ។

ដានីៈ ៧៩ ឬ ៨៩?

សម្បត្តិៈ ៧៩! ទេ ៧៨ ជិត៧៩ហើយ ៧៨ ។

វណ្ណៈ ជំនាន់ខ្មែរក្រហមនៅចាប់ដៃ!

ដានីៈ យួនមិនទាន់ចូលផងកាលនោះ?

សម្បត្តិៈ មិនទាន់ចូលទេ កាលបានជាប៉ុន្មានខែបានយួនចូលមកដល់ ។

ដានីៈ កាលនោះប្រពន្ធពូគាត់ធ្វើអីដែរ?

សម្បត្តិៈ ធ្វើនារីតម្បាញ ។

ដានីៈ នារីតម្បាញនៅឯណា?

សម្បត្តិៈ នៅសាលាកូលេសនោះឯង ថ្មពួក ។

ដានីៈ នារីតម្បាញរបស់ស្រុកថ្មពួក ឬតំបន់?

សម្បត្តិៈ បាទ! របស់ស្រុក ។

ឡាយុំៈ ស្អាតអត់ពូ?

សម្បត្តិៈ នោះ! រូបថត មើល!

ឡាយុំៈ ទេ! ចង់និយាយថានារីតម្បាញកាលហ្នុងនៅតែក្នុងម្ហូប!

សម្បត្តិៈ ទៅសួងទៅដកដូចតែគ្នា មិនសូវដែលបានតម្បាញអី ។

ឡាយុំៈ អ្នកណាអ្នកស្នើរអន្តការ?

សម្បត្តិៈ ខ្ញុំអ្នកស្នើរ ចាំមើលណា បងថ្លៃខ្ញុំ អ្នកភៀននោះ មេកងខ្ញុំ ។

ឡាយុំៈ ហីគាត់ប្រាប់ថាឲ្យ...

សម្បត្តិៈ ទេ! ខ្ញុំឃើញខ្លួនឯងទេ ស្នើរសុំទៅ ស្នើរសុំគេយកឈ្មោះផ្សេងមកទៀត ឈ្មោះផ្សេង ឈ្មោះភឿត ដូចគ្នា កូនតាយុល នៅ...

ឡាយុំៈ ឈ្មោះដូចមុខខុស?

សម្បត្តិៈ ហ្នឹងហើយ! មកអត់ចាប់ដៃទេ អត់ចាប់ដៃដាក់ទារុណកម្មធ្វើកិច្ចសន្យាអីខ្ញុំណា ខ្ញុំក៏ធ្វើកិច្ចសន្យាខ្លាចអី ថាលោកឯងអត់មានថ្ងៃក្រោយទៀតទេ ស្នើរសុំធ្វើប្រពន្ធកូនអីអត់មានទេ ផ្ដិតមេដៃ ប៉ុ រាម ហ្នឹងឯង ខ្ញុំថាអត់ៗទៅ ខ្ញុំចិត្តខ្លាំងផង ដល់លើកក្រោយទៀតតើសបាន បងលួង អន្ទូវ...បានស្នើរទៅបានគេយកមកត្រូវ ចាប់ដៃ មិនទាន់បានចាប់ដៃផង ទឹងនោះ ទឹង ។

ដានីៈ ពូអាចរើសបានកាលហ្នុង?

សម្បត្តិៈ ហ្នឹងហើយរើសបាន

ដានីៈ ប៉ុន្តែ អ្នកខ្លះអត់ទេ?

សម្បត្តិៈ អត់បានទេ ដូងបាត់ទៅហើយ ខ្ញុំមិនសូវដែលខ្លាចផង ។

ដានីៈ ដល់រៀបការហើយក៏នៅជាមួយរហូតមកដល់សព្វថ្ងៃ?

សម្បត្តិៈ មកដល់សព្វថ្ងៃ ។

ដានីៈ សំណួរចុងក្រោយពូ មកដល់សព្វថ្ងៃពូមានដែលឮពត៌មានទាកទងពីសាលាក្ដីកាត់ទោសខ្មែរក្រហមទេ ដែលឮពត៌មានហ្នឹងទេ?

សម្បត្តិៈ ធ្លាប់ឮ!

ដានីៈ ពេលថ្មីៗនេះសវនាការកាត់ទោសឌុច មេគុកទួលស្លែងអីហ្នឹងពូបានដឹងបានមើលទេ?

សម្បត្តិៈ បាទ! បានមើលតាមទូរទស្សន៍ដែរ ។

ដានីៈ ពូយលឃើញម៉េចដែរ ចំពោះសាលាក្ដីកាត់ទោសឌុចហ្នុង?

សម្បត្តិៈ អាហ្នឹងយល់របៀបម៉េច?

ដានីៈ អំពីចិត្តរបស់ពូផ្ទាល់ណា ពូយល់ឃើញថាតើសសាលាកាត់ក្ដីឌុចហ្នឹងត្រឹមត្រូវឬមិនត្រឹមត្រូវ ត្រឹមត្រូវដោយសារមូលហេតុ មិនត្រឹមត្រូវដោយមូលហេតុ តាមយោបល់របស់ពូផ្ទាល់ណា!

សម្បត្តិៈ ទេ អានោះ ការសម្លាប់មនុស្សវាខុសហើយវាត្រូវតែកាត់ទោសអីចឹង ។

ដានីៈ ចុះគេកាត់ទោសគាត់ឲ្យជាប់គុក៣៥ឆ្នាំ ហើគេសម្រួលឥឡូវសល់១៩ឆ្នាំអីចឹង ពូគិតថាសមរម្យដែរ ឬក៏មិនសមរម្យទេ?

សម្បត្តិៈ អានោះមិនដឹងយ៉ាំងទេ ថ្នាក់ណាបញ្ញាថ្នាក់ណាអី ថ្នាក់បញ្ញា ថ្នាក់អនុវត្តន៍អីម៉េចៗ ដូចក្រុមបញ្ញារបស់គេក៏មិនដឹង ឬក៏អ្នកដែលធ្វើផែនការខ្លួនឯង វិទារុណកម្មចុះឯង ។

ដានីៈ បាទ! ខ្ញុំដូចជាអស់សំណួរអីត្រូវសួរទាំពូទៀតហើយ អីចឹងពូមានអីចង់សួនាំនូវអ្វីដែលខ្ញុំអត់បានសួរនាំពូ មានអីចង់បន្ថែមទៀត?

សម្បត្តិៈ អត់មានអីទេ!

ដានីៈ បាទ! អីចឹងខ្ញុំអរគុណពូច្រើន!

សម្បត្តិៈ បាទៗ!

ឡាយុំៈ ពូ! វរៈសេនីយ៍!

សម្បត្តិៈ អនុសេនីយទោ ។

ឡាយុំៈ ចាស់ហើយ អត់បានឡើង!

សម្បត្តិៈ អូ! ខ្ញុំមិនដែលបានអស់ប្រាក់ផង! មិនដែលបុកយកលុយអី ឈ្មោះលឹម ហុង ។

ឡាយុំៈ អត់ប្ដូរឈ្មោះទេ ។

«ចប់»